**BMI0015**

# សម្ភាសន៍ជាមួយឈ្មោះ ពត វុន ភេទស្រី អាយុ៧៥ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហម“យោធា”

## មុខងារបច្ចុប្បន្ន“កសិករ”

ស្រុកកំណើតនៅភូមិអន្លង់ឫស្សី ឃុំស្នាអន្សា ស្រុកក្រគរ ខេត្តពោធិ៍សាត់

រស់នៅភូមិត្រសេកជ្រុំ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ សោម ប៊ុនថន

០០ៈ៣៧ៈ៣៥

១៧ទំព័រ

ប៊ុនថនៈ ចឹងជាដំបូងខ្ញុំចង់សម្ភាសន៍អ៊ំ ទាក់ទងហ្នឹងប្រវត្តិរបស់អ៊ំពីឆ្នាំ៧៩អ៊ំមករស់នៅហ្នឹងអីណាស់ ចឹងជាដំបូងខ្ញុំចង់សួរឈ្មោះអីដែរ?

វុនៈ ឈ្មោះវុន ។

ប៊ុនថនៈ ឈ្មោះអី វុន?

វុនៈ ពត វុន ។

ប៊ុនថនៈ ចឹងអ៊ំអាយុប៉ុន្មានហើយ?

វុនៈ ខ្ញុំអាយុ៧៥ហើយ ។

ប៊ុនថនៈ អាយុ៧៥តែនៅមាំ ។

វុនៈ សើច...សំខាន់ឈឺចន្លាក់ ។

ប៊ុនថនៈ ចឹងអ៊ំមានស្រុកកំណើតនៅណា?

វុនៈ ស្រុកកំណើតខ្ញុំនៅខេត្តពោធិសាត់ ។

ប៊ុនថនៈ នៅភូមិអីដែរ?

វុនៈ ភូមិស្នាអន្សា ។

ប៊ុនថនៈ ភូមិអីវិញ?

វុនៈ ភូមិអន្លង់ឫស្សី ។

ប៊ុនថនៈ ឃុំ?

វុនៈ ឃុំស្នាអន្សា ។

ប៊ុនថនៈ ឃុំថ្នាអន្សា?

វុនៈ ស្នាអន្សា ស្រុកគគ ខេត្តពោធិសាត់ ។

ប៊ុនថនៈ ចឹងអ៊ឹមានបងប្អូនប៉ុន្មាននាក់ដែរ?

វុនៈ បងប្អូនខ្ញុំងាប់អស់ហើយ ។

ប៊ុនថនៈ ពីដើមមកមានប៉ុន្មាននាក់ដែរ?

វុនៈ ពីដើមមានបីនាក់ ។

ប៊ុនថនៈ អ៊ឹជាកូនទីប៉ុន្មាន?

វុនៈ ខ្ញុំកូនទី៧ ។

ប៊ុនថនៈ ចឹងអ៊ឹមានបងប្អូន៨ចឹង?

វុនៈ ចាស!ងាប់អស់ហើយ ។

ប៊ុនថនៈ គាត់ស្លាប់យូរហើយនៅ?

វុនៈ ស្លាប់យូរហើយតាំងពីសង្គ្រាមលន់ នល់នោះ ធ្វើទាហាននោះ ។

ប៊ុនថនៈ គាត់ធ្វើទាហាន?

វុនៈ ទាហានលន់ នល់នោះ ។

ប៊ុនថនៈ ស្លាប់ប្រុសឬស្រី?

វុនៈ ស្លាប់ប្រុសបងប្អូនស្រីមានតែពីរនាក់ទេ ។

ប៊ុនថនៈ ចឹងឪពុកម្តាយអ៊ឹសព្វថ្ងៃគាត់នៅរស់ទេ?

វុនៈ អត់ទេ គាត់ស្លាប់អស់ហើយ ។

ប៊ុនថនៈ គាត់ខូចយូរហើយនៅ?

វុនៈ គាត់ខូចយូរហើយ ខ្ញុំមិនសូវដឹងដែរ ខ្ញុំនៅនេះយូរហើយមិនដែលទៅស្រុកផង ។

ប៊ុនថនៈ អត់ដែលទៅលេងទេ?

វុនៈ អត់ ។

ប៊ុនថនៈ ចឹងតាំងពីបែកមកនៅហ្នឹងរហូត?

វុនៈ ចាស ។

ប៊ុនថនៈ តែមាននៅចាំបងប្អូនទេ?

វុនៈ ឃើញចេះតែចាំហើយ ។

ប៊ុនថនៈ តែបងប្អូនមានដែលមកលេងអ៊ឹអីទេ?

វុនៈ អត់ទេ បើនៅរស់មានមកហើយបើងាប់ហ្នឹងហើយបានមិនមក ។

ប៊ុនថន: ចឹងអ៊ឹកាលពីតូចមានចូលរៀនដែលទេ?

វ៉ុន: ខ្ញុំរៀនអក្សរដែលតែរៀនបានថ្នាក់ទាប ។

ប៊ុនថន: រៀនបានប៉ុន្មានឆ្នាំដែរ បានយូរទេ?

វ៉ុន: រៀនបានបីឆ្នាំ ។

ប៊ុនថន: រៀននៅសាលាណាអ៊ី?

វ៉ុន: មិនដឹងសាលាណាទេ ភ្លេចអស់ហើយ ។

ប៊ុនថន: តែដឹងថារៀននៅក្នុងភូមិគគហ្នឹង?

វ៉ុន: ចាស ។

ប៊ុនថន: ចឹងនៅពេលអ៊ឹឈប់រៀនអ៊ឹធ្វើអីកាលហ្នឹង?

វ៉ុន: ឈប់រៀនធ្វើស្រែចំការហ្នឹងឯង ។

ប៊ុនថន: ជាមួយឪពុកម្ដាយ?

វ៉ុន: ចាស ។

ប៊ុនថន: អ៊ឹមានចូលកងចូលអីទេ?

វ៉ុន: ចូលកងអី ។

ប៊ុនថន: ចូលកងចល័តអី?

វ៉ុន: ចូលកងដឹកជញ្ជូនគេហ្នឹង ។

ប៊ុនថន: ដឹកជញ្ជូននៅណាវិញ?

វ៉ុន: ដឹកជញ្ជូននៅម៉ាឡៃយើងនេះ ។

ប៊ុនថន: ចឹងមុនហ្នឹងនៅកងចល័តណាវិញ?

វ៉ុន: កងចល័តនៅស្រុក ។

ប៊ុនថន: កងចល័តនៅស្រុក?

វ៉ុន: ខ្ញុំមិនបាននៅកងចល័តដង ខ្ញុំចេញមកយូរហើយ ។

ប៊ុនថន: អ៊ឹចេញទៅខាងណាវិញ?

វ៉ុន: ខ្ញុំចេញមកព្រៃហ្នឹង ។

ប៊ុនថន: ចឹងអ៊ឹមកនេះឆ្នាំ៧៩មែនទេ?

វ៉ុន: ខ្ញុំនៅនេះឆ្នាំ៧៩ហើយ ។

ប៊ុនថន: ចឹងមកពេលរត់ហ្នឹងមកនៅទាំងអស់គ្នា?

វ៉ុន: ចាស ។

ប៊ុនថន៖ កាលអ៊ឹមកនៅជំរំបូងហ្នឹងមកនៅខាងណាវិញ?

វុន៖ ខ្ញុំដំបូងនៅប៉ៃលិន។

ប៊ុនថន៖ ចឹងអ៊ឹនៅប៉ៃលិន?

វុន៖ ខ្ញុំចេញមកនៅប៉ៃលិន ចេញពីប៉ៃលិនបានមកនៅម៉ាឡៃ។

ប៊ុនថន៖ អត់មានទៅចូលថៃអីទេ?

វុន៖ ចូលថៃនៅជំរំ៨៥។

ប៊ុនថន៖ ចឹងកាលនៅប៉ៃលិនមានបានយូរទេ?

វុន៖ បានប៉ុន្មានខែទេ ខ្ញុំរត់មកនៅភ្នំបាដេ។

ប៊ុនថន៖ ទៅប៉ៃលិនហ្នឹងមានមនុស្សច្រើនទេ?

វុន៖ មានមនុស្សរាប់រយ កាលហ្នឹងយួនវៃចូលកាលឆ្នាំប៉ុន្មានទេ ឆ្នាំ៨៥។

ប៊ុនថន៖ ចឹង៨៥អ៊ឹទៅប៉ៃលិនឬមកខាងម៉ាឡៃនេះ?

វុន៖ ទៅប៉ៃលិន។

ប៊ុនថន៖ មនុស្សច្រើនទេ?

វុន៖ មនុស្សច្រើនដូចហ្វូងគោ។

ប៊ុនថន៖ អ៊ឹទៅអ៊ឹរត់ទៅតែម្តងឬមានអ្នកនាំផ្លូវ?

វុន៖ មានអ្នកទទួលខុសត្រូវនាំយើងទៅដែលហ្នឹង។

ប៊ុនថន៖ អ៊ឹនៅខាងប៉ៃលិនហ្នឹងអ៊ឹនៅខាងដឹកជញ្ជូនដែរ?

វុន៖ ចាស។

ប៊ុនថន៖ អ៊ឹចេះបើកឡានទេ?

វុន៖ អត់ទេ។

ប៊ុនថន៖ ចឹងម៉េចដាក់ខាងដឹកជញ្ជូន?

វុន៖ ចុះដឹកជញ្ជូនទូលគ្រាប់ទូអង្ករឲ្យទ័ពហ្នឹងមានតែប៉ុណ្ណឹងឯង មានឡានណាបើកកាលហ្នឹងរត់គេយួនចង់ផាប់នោះ។

ប៊ុនថន៖ ចឹងខាងបដិវត្តខាងមីងមានចេះបើកឡានអីទេ?

វុន៖ មានតែក្មេងៗគេចេះបើក។

ប៊ុនថន៖ ចឹងស្រីៗខ្លះមានចេះបើកដែលមីង?

វុន៖ ចាស!ប្រពន្ធតារឿនអីសុទ្ធតែចេះបើក កាលនៅ៩៣អីពួកហ្នឹងសុទ្ធតែចេះបើកឡានធំៗដែរ ពួកខ្ញុំនៅហ្នឹងអ្នកខ្លះចេះកាណូតអ្នកខ្លះចេះឡាន ខ្លះចេះអាត្រាក់បើកតាមជំនាញ

នាំគ្នាមករៀននៅរោងចក្រឡើងបឹងសំយ៉ាបចេះគ្រប់គ្នា ។ (កន្លែងនេះអ្នកជិតខាងនិយាយរញ៉េរញ៉ៃ) ។

ប៊ុនថន: បាទ!ចឹងមីងបានទៅភ្នំពេញដែរ?

វ៉ុន: បាន ។

ប៊ុនថន: ចុះអីបានទៅភ្នំពេញទេ?

វ៉ុន: អត់ទេខ្ញុំនៅប៉ៃលិន ឆ្នាំ៧៧ខ្ញុំនៅប៉ៃលិន ។

ប៊ុនថន: មីងផ្លាស់មកប៉ៃលិន?

វ៉ុន: ខ្ញុំនៅប៉ៃលិន ខ្ញុំធ្វើចំការកាហ្វេ ។

ប៊ុនថន: ធ្វើចំការកាហ្វេច្រើនទេមីង ប្រហែលជាប៉ុន្មានហិចតាដែរ?

វ៉ុន: ច្រើនណាស់មើលដាច់កន្ទុយភ្នែករាប់រយរាប់ពាន់រ៉ៃ ។

ប៊ុនថន: មនុស្សនៅច្រើនទេ?

វ៉ុន: មានមនុស្សច្រើន គ្រួសារយោធាអីនៅទាំងអស់គ្នា ។

ប៊ុនថន: ឲ្យនៅធ្វើចំការកាហ្វេហ្នឹងតែម្តង?

វ៉ុន: ចាស!ខ្លះធ្វើកាហ្វេខ្លះធ្វើចំការខ្លះ ។

ប៊ុនថន: បានផលទេមីងចំការកាហ្វេហ្នឹង?

វ៉ុន: កាលហ្នឹងធ្វើឲ្យរដ្ឋ បានហ្នឹងឯងកំណត់ផែនការបានប៉ុន្មានតោនៗធ្វើលើស ហើយបេះមិនទាន់មានកងទ័ពមកជួយបេះ ។

ប៊ុនថន: អ្នកមីងនៅចំការកាហ្វេហ្នឹងយូរទេ?

វ៉ុន: ខ្ញុំនៅបានយូរដែលហ្នឹងមួយឆ្នាំពីរឆ្នាំ ដល់យួនចូលមកបានចេញពីហ្នឹងមកពីប៉ៃលិនមក ។

ប៊ុនថន: ចឹងចេញពីប៉ៃលិនមីងមកម៉ាឡៃតែម្តង?

វ៉ុន: ចេញពីប៉ៃលិនមកហ្នឹងតែម្តង ។

ប៊ុនថន: កាលហ្នឹងឆ្នាំណាមកដំបូង?

វ៉ុន: ឆ្នាំ៧៩ ។

ប៊ុនថន: ចឹងកាលមីងមកហ្នឹងមានមនុស្សច្រើនគ្នាទេ?

វ៉ុន: ច្រើន មនុស្សច្រើនណាស់តាំងពីសហករណ៍តាំងសហជីពរត់ពីណាពីណីមកជុំគ្នាមានចាស់មានក្មេងអីពេញព្រៃទាំងអស់ហ្នឹង កាលហ្នឹងវេទនាណាស់កាលរត់ហ្នឹង ។

ប៊ុនថន: ចឹងកាលដំបូងមីងនៅម៉ាឡៃហ្នឹងដូចថាមានផ្ទះមានអីនៅ?

វ៉ុន: មកដំបូងធ្វើកូនខ្ទមនៅ យើងប្រូតស្បៃធ្វើរោងអីនៅទៅ មួយកងៗយើងទៅតាមក្រុម

ចឹងទៅ មួយក្រុមផ្ទះមួយចឹងទៅ ។

ប៊ុនថន: ចឹងម៉ាឡែនេះជាវាលឬមួយមានព្រៃ?

វុន: ព្រៃ ព្រៃខ្លាព្រៃនាម មិនមានពីណាហ៊ានចូលទេពូមុន ដើមឈើធំៗណាស់ ។

ប៊ុនថន: អឹមកធ្វើខ្ទមអីដំបូងនៅម្តុំណា?

វុន: យើងកាលដំបូងនៅមាត់អូរនោះ នៅនេះក៏មានដែលកូនខ្ទមគេមានហូរហែរតាមភូមិហ្នឹង ខ្ញុំកាលពីមុននៅកន្លែងឃ្លាំងចាស់នោះ នៅកន្លែងឃ្លាំងអង្ករចាស់ពីមុន ផ្ទះនេះទើបបកពី៨៥ ហើយបានមកនៅនេះ ។

ប៊ុនថន: បាទ ។

វុន: ផ្ទះកាលមុនតូចៗធ្វើពីឬស្សីអីហ្នឹង យើងរត់ហ្នឹងហើយធ្វើស្រូវបាន៦ទៅ៧បាវមានបានស៊ីណាគ្រាប់ផ្លោងមកពីហ្នឹងទាហានប៉ាវាគេជជ្រុំ រួចទាហានយួននោះ រត់ធ្លាក់ដីថៃផាផាត់ដាក់ញញ្ញាំងបាយឆ្នាំងសម្លស្នានេះរៀបហើយអស់ហើយ ។

ប៊ុនថន: បាទ ។

វុន: អ្នកបន្ទាយទី១បន្ទាយទី២យកមាន់យកទាមកចោលតែនេះ កាលហ្នឹងគេចេញអស់ខ្ញុំក៏មិនទាន់បានចេញដែរ ដល់ទ័ពឲ្យចេញបានចេញគ្រាប់មកធ្លាក់ជិតណាស់ហើយ ត្រង់សេមួយចូលឡើងពីរបីនាក់ដាន់គ្នាណានៅក្រោមៗ "អ្នកជិតនិយាយកាលចូលសាគាំងមួយគ្រាប់បងឯងនៅណា? ខ្ញុំនៅហ្នឹង ខ្ញុំនៅផ្ទះហ្នឹង ។

ប៊ុនថន: ផ្ទះណាមីងនៅជិតណា?

វុន: ខ្ញុំនៅជិតមន្ទីរក្នុងភូមិហ្នឹង ។

ប៊ុនថន: នៅភូមិណា?

វុន: ភូមិដូង ឥឡូវទើបបែងចែកគ្នា គេចែកភូមិអស់ហើយ ។

ប៊ុនថន: ចឹងមកដំបូងហ្នឹងសុទ្ធព្រៃ?

វុន: សុទ្ធតែព្រៃ ព្រៃធំៗព្រៃខ្លាព្រៃនាម កាប់ឈើធ្វើត្រសរផ្ទះយើងមានហត់ទៅកាប់អីណាកាប់នៅនេះឯង ដល់នៅបានយូរទៅបានជាវាលកើតស្រែអីទៅ កាលហ្នឹងកុំតែបានខ្មែរក្រហមនៅតស៊ូប្រហែលជាដីយើងត្រូវអស់ ។

ប៊ុនថន: បាទ ។

វុន: គេវៀតយកឡើងអស់ ។

ប៊ុនថន: ចឹងដូចជាឈ្មោះភូមិអីហ្នឹងទើបគេដាក់ឈ្មោះក្រោយទេអី?

វុន: ចាស ។

ប៊ុនថន: កាលអ៊ឹមកហ្នឹងមានឈ្មោះភូមិដូងអីនៅ?

វ៉ុន: មាននៅភូមិដូងហៅភូមិដូងចឹងទៅ កាលលើកមុនហៅតែភូមិដូងៗទេ មានតែភូមិដូងមួយទេ កាលមុនដំបូងគេ ។

ប៊ុនថន: ក្រៅពីហ្នឹង?

វ៉ុន: ក្រៅពីហ្នឹងមិនទាន់ទេ ទើបតែមកចែកគ្នាទេ ។

ប៊ុនថន: ចឹងភូមិត្រសេកជ្រុំអីមិនទាន់មានទេ?

វ៉ុន: អត់មានទេ មានតែភូមិដូងមួយឯង ។

ប៊ុនថន: ចឹងហៅឈ្មោះម៉េចទៅ?

វ៉ុន: គេហៅភូមិដូងចឹងទៅ អ្នកខ្លះហៅម៉ាឡៃចឹង ម៉ាឡៃទទេមិនដែលដាក់ឈ្មោះភូមិផង ជាពិសេសអ្នកបោះឆ្នោតភាគច្រើនតែម៉ាឡៃ គាត់មិនចាំឈ្មោះ ។

ប៊ុនថន: បាទ ។

វ៉ុន: មិនចាំភូមិបេះតែដាក់ៗទៅ ក្មេងៗជំទង់១៧-១៧ហ្នឹង ។

ប៊ុនថន: ចឹងភូមិត្រសេកជ្រុំអីហ្នឹងយ៉ាងម៉េចបានគេហៅភូមិត្រសេកជ្រុំ?

វ៉ុន: គេបែងចែកគ្នា កាលពីមុនមកគេហៅភូមិស-១៥ទេ ពីមុន ។

ប៊ុនថន: ភូមិស-១៥?

វ៉ុន: ចាស!ភូមិស-១៥ពីមុនមកក្មេងៗគេទៅរៀនអីគេមិនដាក់នៅចុងខាងលិននេះ ហើយមានវត្តថៃនៅក្បែរយើងត្រង់នេះពីមុនមក ។

ប៊ុនថន: បាទ ។

វ៉ុន: តែឥឡូវថៃគេខិតទៅនោះហើយ វត្តយើងមាននៅនេះដែរយើងវត្តចាស់ហ្នឹង ។

ប៊ុនថន: បាទ ។

វ៉ុន: ឥឡូវកើតទៅវត្តថ្មី បែកទៅខាងនោះវិញ ។

ប៊ុនថន: បាទ ។

វ៉ុន: គេរៀបចំភូមិថ្មីចឹងទៅ គេបែកចែកភូមិចឹងទៅចែកឈ្មោះចឹងទៅ មានភូមិកណ្ដាលមានភូមិថ្មី មានគោកវិល មាន១០៧មានភូមិវត្តចាស់ មានភូមិត្រសេកជ្រុំ កាលនេះដាក់ ១០៦ ។

ប៊ុនថន: ភូមិ១០៦?

វ៉ុន: ចាស!១០៦ពីមុនតែឥឡូវបែងចែកដាក់ត្រសេកជ្រុំ ។

ប៊ុនថន: ត្រសេកជ្រុំហ្នឹងមកពីមានសត្វសេក?

វុន៖ កាលពីមុនមានដើមត្រសេកច្រើនណាស់តែឥឡូវគេកាប់ចោលអស់ មានដើមឫស្សីអីទេ គេដាក់ជួនៗគ្នា ជួនតាមភូមិ ។

ប៊ុនថន៖ ចឹងកាលអឹមកធ្វើខ្ទមនៅហ្នឹងអឹនៅខាងដីកជញ្ជូនអី?

វុន៖ ដីកជញ្ជូន ។

ប៊ុនថន៖ បាទ!ចឹងរបបហូបចឹង?

វុន៖ មានអីរបបហូប របបអង្ករមានសព្វមុនហូបមិនអស់ដុះផ្សិតជន្លួវស៊ីទៀតហើយកាលហ្នឹង មិនមានចាយលុយទេ កាលនៅជាមួយអឹៗអត់មានចាយលុយ ចាយអង្ករដូរថៃទៅវិញ អត់ដូទេ យើងនៅនេះមានថៃណាដូរ(គាត់ជជែកគ្នាគាត់) ។ កាលយើងចូលទៅនោះដូថៃ យើងនៅនេះអត់ទេ កាលហ្នឹងគេបើកឲ្យហូបត្រីខខ្ញាញ់ប៊ីចេងស្ករប្រហុកអំបិល សាប៊ូអី មួយចប់ ។

ប៊ុនថន៖ បាទ ។

វុន៖ អត់មានខ្វះអីទេ ។

ប៊ុនថន៖ បើកតាមចំនួនមនុស្សឬតាមគ្រួសារ?

វុន៖ តាមចំនួនគ្រួសារ គេបើកតាមក្រុមតាមកង ។

ប៊ុនថន៖ ចឹងប្រជាជនធម្មតាយើងបើកតាម?

វុន៖ ប្រជាជនធម្មតាបើកតាមគ្រួសារ ។

ប៊ុនថន៖ ចឹងបើសមាជិកគ្រួសារមាន៥នាក់ចឹង?

វុន៖ បើកតាម៥នាក់ចឹង ៧នាក់ដាក់៧នាក់ទៅ១០នាក់ដាក់១០ទៅ មានហូបបបូរអ្នកណាគ្នា ច្រើនបានច្រើន ។

ប៊ុនថន៖ បាទ ។

វុន៖ អង្ករតាមឃ្លាំងកាលមុនដាក់បាវធំៗ អស់ពីបាវធំខាងកាកបាទកូនថង់តូចប៉ុនៗនេះ ។

ប៊ុនថន៖ បាទ ។

វុន៖ ថង់យើងថង់សហ្នឹងថង់ផ្លាស់ស្ទិចហ្នឹង បើកនៅកន្លែងព្រលាន ។

ប៊ុនថន៖ បាទ ។

វុន៖ កុំតែបានអឹៗពីមុនយើងត្រូវសូន្យអស់ខ្មែរបានតស៊ូទៅមុខទៀតហើយ កុំតែបានគាត់ ។

ប៊ុនថន៖ ចឹងអឹអត់មានបានទៅដល់ថៃអីទេ កាលហ្នឹង?

វុន៖ ចុះកាលចូល៨៥ហ្នឹង ម៉ាឡៃកាលធ្លាក់គ្រាប់ផ្លោងហ្នឹងចូលទៅថៃនៅ៨៥ ។

ប៊ុនថន៖ ៨៥ហ្នឹងអឹទៅថៃដែរ?

វុន៖ ថៃ៨៥ហ្នឹង ។

ប៊ុនថន៖ អ៊ីរត់ទៅជំរំឬមួយទៅនៅណា?

វុន៖ នៅជំរំ៨៥ហ្នឹង អត់មានទៅដល់កាង៉ុកអីទេ នៅជំរំ៨៥ហ្នឹងតែម្តង ។

ប៊ុនថន៖ កាលហ្នឹងឆ្នាំណាអ៊ីរត់ទៅហ្នឹង?

វុន៖ ឆ្នាំ៨៤-មិនដឹងជាប៉ុន្មាន៨៥ហ្នឹង ។

ប៊ុនថន៖ ឆ្នាំ៨៥អ៊ី?

វុន៖ ចាស ។

ប៊ុនថន៖ អ៊ីទៅនៅហ្នឹងសុទ្ធតែកងទ័ពតែម្តងនៅជំរំ៨៥ហ្នឹង?

វុន៖ គ្រួសារយោធាប្រជាជនគ្រប់ចំរុះគ្នា ។

ប៊ុនថន៖ ចឹងអ៊ីតែម្នាក់អីទៅ?

វុន៖ ខ្ញុំនៅម្នាក់ឯងខ្ញុំនៅជាមួយកងដឹកជញ្ជូន ។

ប៊ុនថន៖ គេហៅកងដឹកជញ្ជូនតែម្តងឬមួយគេមានលេខមានអីដែរ?

វុន៖ មិនបានមានលេខទេ មេកងគេមានចាំយើងកូនកងមិនបានចាំទេ ។

ប៊ុនថន៖ កាលអ៊ីទៅនៅជំរំ៨៥ហ្នឹងយូរដែរ?

វុន៖ យូរដែលតើ នៅប៉ុន្មានខែទេ នៅពីរបីឆ្នាំដែលហ្នឹងណាស់ ពីរឆ្នាំដែរបីឆ្នាំដែលបានយើងបានធ្វើរោងយើងបានប្តីហ្នឹង មិនដល់មួយឆ្នាំទេដឹងភ្លេចហើយ ។

ប៊ុនថន៖ ចឹងបានចូលមកនៅហ្នឹងវិញ?

វុន៖ ចាស!ចូលមកនៅនេះឆ្នាំ៩១-៩២ កាលហ្នឹង៩១បានចូលមកនៅវិញ ។

ប៊ុនថន៖ ចឹងកាលពេលវៃជាមួយវៀតណាមហ្នឹង ដែលមានវៀតណាមចូលដល់ព្រំដែនទេ?

វុន៖ ចូលដល់នេះឯង ដល់ហើយបានជាពួកខ្ញុំរត់ចេញទៅនោះ កាលហ្នឹងផ្លោងពីភ្នំយាយសំហ្នឹងមកពួកខ្ញុំរត់កាប៉ាំងដើង កាលហ្នឹងមានអីឥវ៉ាន់មានតែធ្យូងយើងដុតទុកយកដូរបារីថៃដក់អស់ ។

ប៊ុនថន៖ បាទ ។

វុន៖ កាលហ្នឹងដល់សាគាំងដែរ ។

ប៊ុនថន៖ អត់មាននៅបានយូរទេអ៊ី?

វុន៖ នៅមិនបានយូរទេ មកបានតែមួយភ្លេត យើងដេញឡប់ទៅវិញ ងាប់ច្រើនគ្នាណាស់កាលហ្នឹង ងាប់ឡើងមិនចេះតិចចាញ់ទឹកដី ។

ប៊ុនថន៖ ងាប់ទាហានវៀតណាមឬកំលាំងបដិវត្ត?

វុនៈ ផាប់កំលាំងខ្មែរមិនដឹងទាហានវៀតណាមមិនដឹងបើយើងមិនដែលមកផង បើយើងនៅដីថៃនោះ ។

ប៊ុនថនៈ បាទ ។

វុនៈ មានយើងខ្លះមានយួនខ្លះហ្នឹងឯង ទាហានប៉ុលពតស្លាប់ខ្លះទាហានខ្មែរស្លាប់ខ្លះ ទាហានខ្មែរក្រហមនៅលាយគ្នាហ្នឹង កាលហ្នឹងមិនបាកទាញមីនផងនៅកន្លែងសារតាំងកាច់ផាប់បណ្តោយ ចាញ់បារមីសម្តេច កាលហ្នឹងគ្រាប់ផ្លោងចូលអត់មានត្រូវបួសមនុស្សអីអត់មានទេ ។

ប៊ុនថនៈ បាទ ។

វុនៈ ចូលដល់កន្លែងហ្នឹងបារមីលោកខ្លាំងណាស់ ។

ប៊ុនថនៈ កាលហ្នឹងមានមីនច្រើនទេ?

វុនៈ មីនកាលមុនក្រាល កាល(ក-៥)រហូតដល់មាត់អូរជិត ។

ប៊ុនថនៈ ឆ្នាំណាមីងមីនដែលគេដាក់ហ្នឹង?

វុនៈ ឆ្នាំដែលយួនចូលមកហ្នឹង ឆ្នាំដែលយើងរត់ទៅ៨៥ហ្នឹង យើងចេញគេចូល ៨៤-៨៥ហ្នឹង ។

ប៊ុនថនៈ ចឹង៨៤-៨៥ហ្នឹងចាប់ផ្តើមដាក់មីនហើយ?

វុនៈ ចាស!យួនចូលហើយ យួនចេញហើយគេដាក់មីនហើយ កាលលើកមុនឃ្លាំងយើងមានដែលឃ្លាំងគ្រាប់ផ្លោង មានឃ្លាំងអង្ករអីមានទាំងអស់ មីមានទាំងឡាំងបញ្ជូនទៅកងទ័ពហូបទៅ នំឈូបៗទាំងធុងៗមកពីចិន មិនចង់ហូបផង ។

ប៊ុនថនៈ បាទ ។

វុនៈ ខ្ញុំមែនទែនហូបមីឡើងបាក់ ។

ប៊ុនថនៈ នំឈូបដូចម៉េចមីង?

វុនៈ នំឈូបរាងវាប៉ុននេះតែរាងប្រផេះសាច់ឡើងម្ចត់ស្អាតណាស់ ដូចសណ្តែកដីយើងចឹងឡើងម្ចត់ស្អាតពីរផ្អាប់ហ្នឹងតែបួនជ្រុង ។

ប៊ុនថនៈ បួនជ្រុងហើយផ្អែមទេ?

វុនៈ ផ្អែមហើយដាក់ថង់ យកទៅឲ្យទ័ពយើងដឹកជញ្ជូនទៅ ។

ប៊ុនថនៈ បាទ ។

វុនៈ គ្រួសារយោធាប្រជាជនអីបើកទាំងអស់ មានទឹកដោះគោស្ករបីចេងមានអំបិលប្រហុកសាច់ប៉ូវត្រី បើខ្វាញ់វិញខ្ចិលឡើងកាដុងមាន៦ធុងប៉ុននេះ ។

ប៊ុនថន:	បាទ ។

វុន:	គរអត់មានខ្វះស្អីទេ មានសប់មានសណ្តែកបាយអីចែក មានក្រណាត់អីកែវ។ប៉ុណ្ណោះ នោះ មានមានក្រប៉ុន បើការីកាប៉ុនវិញសុទ្ធតែប៉ុននេះ។ ។

ប៊ុនថន:	បាទ ។

វុន:	សាច់គោសាច់ជ្រូកសាច់មាន់ដឹកជញ្ជូនមកឆ្អែះមើលមានអាណាឆ្ងាញ់ បើកាលពី៧៩រកតែ អីបង់គ្មានទេ ។

ប៊ុនថន:	បាទ ។

វុន:	៧៩ខ្ញុំក៏មិនធ្វើអីដែរ មកធម្មតា ខ្ញុំកាលនៅគ្រាវបានយ៉ាប់គ្នាមួយកំប៉ុងគ្នា៦នាក់ ។

ប៊ុនថន:	ចឹងកាលអ៊ំនៅដឹកជញ្ជូនហ្នឹងដល់ឆ្នាំណា?

វុន:	ខ្ញុំកាលឈប់មិនដឹងជាឆ្នាំប៉ុន្មានដែរទេ កាលនៅដីថៃខ្ញុំនៅប្រចាំការព្រំដែន ទើបមកឈប់ ឆ្នាំ៩០ប៉ុន្មាននេះ៩១-៩២ហ្នឹងឯង ។

ប៊ុនថន:	ចឹងកងដឹកជញ្ជូនមានគ្នាច្រើនទេ?

វុន:	មានច្រើនទាំងប្រុសទាំងស្រី ។

ប៊ុនថន:	ទាំងប្រុសទាំងស្រីលាយគ្នា?

វុន:	ចាស!ប្រជាជនក៏ដឹកជញ្ជូនដែរ ។

ប៊ុនថន:	កាលហ្នឹងដឹកជញ្ជូនហ្នឹងមានអីខ្វះអីមានដឹងទេ?

វុន:	មានអង្ករមានគ្រាប់មានត្រីខមានមីមានទឹកដោះគោ ជញ្ជូនឲ្យទ័ពមួយចប់ គ្រាប់ កាំភ្លើង ពីណាលី។ទៅ ។

ប៊ុនថន:	ចឹងដូចថាអ៊ំនៅខាងដឹកជញ្ជូនហ្នឹងមានចេះបាញ់អីទេ?

វុន:	អត់ទេ ចេះតែខាងពួ។ទេ ស្រីសុទ្ធតែដឹកជញ្ជូនមួយនេះក៏ដឹកជញ្ជូនដែរ ។

ប៊ុនថន:	តែមានស្រីប្រុសលាយគ្នាអ៊ី?

វុន:	ទ័ពគេនៅប្រចាំស្រី។ដឹកជញ្ជូនទៅមុខសមរភូមិចឹងមានអ្នកការពារប្រុស។ទ័ពណាស់ ។

ប៊ុនថន:	បាទ ។

វុន:	ដើរមុខដើរក្រោយយើងនារីដើរកណ្តាលទៅ ការពារយើងខ្លាចយួនទាញមីនអីណាស់ ។

ប៊ុនថន:	បាទ ។

វុន:	កាលហ្នឹងយួនវាត្រៀមដែលហ្នឹងណាស់ យើងដឹកជញ្ជូនយ៉ាប់ដែលហ្នឹងណាស់ ។

ប៊ុនថន:	បាទ ។

វុន:	មិនចេះតែទៅលាំង។ណាបានកាលហ្នឹង ។

ប៊ុនថន: ចឹងអត់មានឡាន់ដឹកទៅទេ?

វុន: អត់ទេ ឡានខាងក្រោយថីមានតែយើងដឹកទៅតាមណាសមរភូមិ កាលហ្នឹងយើងជញ្ជូនបណ្តាក់ៗហ្នឹង បើជញ្ជូនដឹកឃ្លាំងបានឡាន បើទៅមុខយើងមិនហ៊ានបើកទេ បើយើងបើកឡាន យួនវាដឹងវានៅគៀកយើងដែរ ។(អ្នកជិតនិយាយថា កាលខ្ញុំធ្វើស្រែនៅបាប៉ុងបានអស់ទាស់អាដើងបន្តងវាបាញ់ ឃើញទូកពួកខ្ញុំឡើងអណ្តែតគ្រាវាស្មានថាយើងជញ្ជូនស្បៀងយកទៅឲ្យទ័ពកំពង់តែហូបបាយជុំគ្នាហ្នឹងគ្រេតៗ ៗចំឆ្នាំងបាយតែមិនចំនុស្សមនុស្សឡើងជុំគ្នាតែមិនអី កុំនៅកណ្តាលបឹងសោ្ទះ នៅជិតទន្លេមេគង្គ) ។

ប៊ុនថន: ចឹងខ្ញុំសួរអ៊ីវិញ កាលអ៊ីទៅធ្វើចំការកាហ្វេនៅប៉ៃលិនហ្នឹងអ៊ីនៅណាវិញ?

វុន: ខ្ញុំនៅលាច ។

ប៊ុនថន: នៅលាចនៅពោធិសាត់ទេ?

វុន: ចាស!នៅពោធិសាត់ ។

ប៊ុនថន: កាលនៅលាចហ្នឹងអ៊ីនៅកងអីវិញ?

វុន: នៅកងចល័ត ។

ប៊ុនថន: គេហៅកងចល័តអីវិញកាលហ្នឹង?

វុន: កងចល័តស្ទូងដឹកប្រឡាយប៉ុណ្ណឹងឯង ។

ប៊ុនថន: គេហៅកងចល័តលាចចឹងតែម្តង?

វុន: យើងនៅកងចល័តហ្នឹងតែយើងនៅលាច នៅកងចល័តមិនឃើញមានឈ្មោះអីផង ។

ប៊ុនថន: ចឹងបងៗរបស់អ៊ី?

វុន: បងៗខ្ញុំគាត់ធ្វើទ័ពតាំងពីសម័យលន់ នល់មិនដែលបានជួបគ្នាទេ មិនបានជួបរហូតមកដល់ឥឡូវនេះ ។

ប៊ុនថន: ចុះម្តាយឪពុក?

វុន: ម្តាយឪពុកខ្ញុំក៏ចឹងដែរ គាត់នៅតាមប្រជាជននេះ នៅតាមសហករណ៍ ។

ប៊ុនថន: ចឹងអ៊ីធ្វើកងចល័តហ្នឹងបែកម្នាក់ឯងមក?

វុន: បែកតែឯងរហូតមក អ្នកនៅភាគច្រើនក្បាលតែមួយទេ ខ្ញុំនៅលាចទៅពីលាចទៅនៅកោះកុង ៧៧ខ្ញុំមកពីកោះកុងបានមកនៅប៉ៃលិន ។

ប៊ុនថន: កាលនៅកោះកុងហ្នឹងអ៊ីទៅធ្វើអីវិញ?

វុន: នៅកោះកុងនៅដាំបាយឲ្យពួកទ័ព ។

ប៊ុនថន: ចឹងអ៊ីនៅហ្នឹងបានមួយឆ្នាំដែរ?

វុនៈ	នៅហ្នឹងអត់មានបានមួយឆ្នាំមែនទេ ៧៧-៧៨ខ្ញុំមកវិញហើយ ។

ប៊ុនថុនៈ	៧៨មក?

វុនៈ	មកប៉ៃលិន ។

ប៊ុនថុនៈ	ចឹង៧៨អត់មានទៅភូមិទេ ទៅប៉ៃលិនតែម្ដង?

វុនៈ	អត់មានដែលទៅភូមិតាំងពីចេញមកតាំងពីឆ្នាំ៧០របូតមិនដែលឃើញផ្ទះទេ មិនដែលឃើញភូមិស្រុកផង ។

ប៊ុនថុនៈ	ចឹងអ៊ីបែកពីផ្ទះតាំងពីឆ្នាំ៧០?

វុនៈ	ចាស!ឆ្នាំ៧០ ។

ប៊ុនថុនៈ	ចឹងឆ្នាំ៧០អ៊ីចូលបដិវត្ត?

វុនៈ	ចាស ។

ប៊ុនថុនៈ	អ៊ីចូលនៅណាវិញដឹបូង?

វុនៈ	សួរចឹងភ្លេចអស់ហើយ ។

ប៊ុនថុនៈ	ចឹងអ៊ីចូលតាំងពីអាយុប៉ុន្មានមានចាំអាយុទេ?

វុនៈ	អត់មានចាំទេ ។

ប៊ុនថុនៈ	ចូលហើយអ៊ីនៅលាចរហូតឬមួយអ៊ីនៅណាវិញ?

វុនៈ	នៅលាចហ្នឹង ចូលកងចល័តនៅលាចហ្នឹងឯង មានចូលបដិវត្តអីកាលហ្នឹងកងចល័តគេមករើសយកមនុស្សគគោក កងចល័តកាលហ្នឹងធ្វើស្រែធ្វើប្រឡាយនោះណា ។

ប៊ុនថុនៈ	បាទ!តាំងពី៧០ហ្នឹង?

វុនៈ	ចាស ។

ប៊ុនថុនៈ	ចឹងក្រោយមកនៅហ្នឹងរហូតដល់ឆ្នាំ៧៧អ៊ី?

វុនៈ	មិនដឹងជាឆ្នាំណាទេ កោះកុង ។

ប៊ុនថុនៈ	កាលចូលហ្នឹងអ៊ីនៅជុំជាមួយឪពុកម្ដាយឬមួយបែកគ្នាហើយ?

វុនៈ	បែករហូតហ្នឹង ។

ប៊ុនថុនៈ	គេឲ្យចល័តទៅភូមិនេះភូមិនោះទៅ?

វុនៈ	ចាស ។

ប៊ុនថុនៈ	តាំងពី៧៧អ៊ីមានដែលឮដំណឹងគាត់ដែរ?

វុនៈ	មិនដែលឮទេ ។

ប៊ុនថុនៈ	មិនដែលសរសេរសំបុត្រទាក់ទងគ្នាទេ?

វ៉ុនៈ អត់ទេ ។

ប៊ុនថនៈ ចឹងអ្នកភូមិអ៊ឹះអីមាននៅធ្វើការជាមួយអ៊ឹះទេ?

វ៉ុនៈ អត់ទេ អ្នកភូមិអ្នកស្រុកខ្ញុំឥឡូវអត់មានពីណានៅនេះដែរ ។

ប៊ុនថនៈ បែកគ្នារហូតអ៊ឹះ?

វ៉ុនៈ បែករហូត ។

ប៊ុនថនៈ អ៊ឹះនៅតែម្នាក់ឯង?

វ៉ុនៈ នៅតែម្នាក់ឯង ។

ប៊ុនថនៈ ចឹងនៅខាងពោធិសាត់នោះមានដែលសួររកអីដែរ ដូចបងប្អូនជីដូនមួយអី?

វ៉ុនៈ អត់ដែលមានអ្នកស្រុកអ្នកភូមិណាមកនេះបាន ដឹងដំណឹងណាអត់ផង ។

ប៊ុនថនៈ ចឹងអ៊ឹះមាននៅចាំភូមិដែរបើទៅស្គាល់ទេ?

វ៉ុនៈ បើទៅស្គាល់ហើយ ។

ប៊ុនថនៈ ចឹងមកហើយចឹងអ៊ឹះមានចង់ទៅលេងនឹកផ្ទះអីចឹង?

វ៉ុនៈ ចឹងតែនឹកដែលចឹងឯងយើងអត់មានលុយ ឥឡូវគេចាយតែលុយយើងអត់មានលុយទៅម៉េចរួច ។

ប៊ុនថនៈ បាទ ។

វ៉ុនៈ បើមានលុយចេះតែទៅលេងហើយ ទៅរកបងប្អូនហើយនឹកដែលស្រុកកំណើត បែកក្មួយតាំងពីតូចៗឥឡូវមើលក្មួយលែងស្គាល់ហើយ ចុះកាលយើងបែកខ្លះវាមិនទាន់កើតផង យើងម៉េចស្គាល់គេ ខ្លះដើរបុកគ្នាមិនស្គាល់ផង "អ្នកជិតនិយាយកាលខ្ញុំទៅលេងមួយល្វែងផ្ទះអង្គុយពីនោះមកសុទ្ធតែក្មួយ ។

ប៊ុនថនៈ បាទ ។

វ៉ុនៈ សុទ្ធតែជីដូនមួយជីទួតមួយទៅអត់មានស្គាល់ពីណា ថាកុំប្រកាន់គ្នា គ្នាចេញតាំងពីតូចៗ ។

ប៊ុនថនៈ បាទ ។

វ៉ុនៈ តាំងពីឆ្នាំ៧០-៧១នោះ ។

ប៊ុនថនៈ ចឹងបើបងប្អូននៅក៏មិនស្គាល់ដែរ?

វ៉ុនៈ ទេ បើបងប្អូនស្គាល់ ក្មេងៗក្មួយៗមិនស្គាល់ទេ ក្មួយមិនស្គាល់មីង មីងមិនស្គាល់ក្មួយផងចុះបែកយូរហើយ ។

ប៊ុនថនៈ តាំងពីឆ្នាំ៧០?

វុនៈ ចាស ។

ប៊ុនថនៈ តាំងពី៧០គិតទៅ៨០ឆ្នាំហើយ?

វុនៈ ចាស ។

ប៊ុនថនៈ ចឹងតាំងពីបែកមកអ៊ីអត់មានគ្រួសារទេ?

វុនៈ អត់ ។

ប៊ុនថនៈ អត់មានរហូតនៅម្នាក់ឯង?

វុនៈ ចាស!កាលនោះការងារដល់ហើយមាននឹកឃើញណា កាលហ្នឹងសប្បាយណាស់ថ្សិតតែចឹងតែសប្បាយអត់មានធ្វើខ្លួនដូចសម័យនេះទេ សម័យនេះវាជឿនលឿនជ្រុលពេកមិនចង់បានទេ ចង់បានប្រវត្តិដើមវិញស្រួលណាស់ ។

ប៊ុនថនៈ បាទ!អ៊ីមកនៅធ្វើផ្ទះនេះឆ្នាំណា?

វុនៈ ឆ្នាំ២០០១ ។

ប៊ុនថនៈ ឆ្នាំ២០០១ ។

វុនៈ ចាស ។

ប៊ុនថនៈ ចឹងរដ្ឋចែកដីឲ្យអ៊ី?

វុនៈ ចាប់ខ្លួនឯងហើយបងប្អូនដែលគេរាប់អានហ្នឹងគេចាប់ឲ្យយើង យើងមកនៅទៅ ។

ប៊ុនថនៈ ចឹងអ៊ីមានចំការមានអីដែលអ៊ី?

វុនៈ មានចំការតិចតួច តិចតួចអត់លុយធ្វើក៏មិនធ្វើដែលហ្នឹង ជួលឲ្យគេបានលុយតិចតួចគ្រាន់ទិញអង្ករហ្នឹងឯង ។

ប៊ុនថនៈ ចឹងចង់សួរបន្តទៀតដីអីចាប់ខ្លួនឯងតែម្តង?

វុនៈ ក្មួយគេចាប់ឲ្យ បងប្អូនរាប់អានគេចាប់ឲ្យ ។

ប៊ុនថនៈ ចាប់ធ្វើផ្ទះឲ្យទៅ?

វុនៈ ចាស! គាត់អត់ចឹងទៅអត់មានលុយទិញបាយទិញអង្ករអីចឹងក្មួយជួយ ។

ប៊ុនថនៈ ក្មួយមិនមែនក្មួយបង្កើតណា?

វុនៈ ក្មួយស្គាល់រាប់អានគ្នាហ្នឹងណាស់ ។

ប៊ុនថនៈ ចឹងនៅម្តុំហ្នឹងសុទ្ធតែស្គាល់ទាំងអស់ធ្លាប់ធ្វើការជាមួយគ្នា?

វុនៈ ស្គាល់គ្នារាប់អានដូចបងប្អូនបង្កើតចឹង បើដូចសម័យខ្មែរក្រហមវិញដូចបងប្អូនបង្កើតចឹង ។

ប៊ុនថនៈ ជួយគ្នាឈឺស្កាត់អីចឹង?

វ៉ុនៈ ជួយគ្នាឈឺស្កាត់យប់ប្រលប់អីចឹង ទៅមន្ទីរពេទ្យអីជួយគ្នាទាំងអស់ ។

ប៊ុនថនៈ ចឹងអ៊ីក្រោយសមាហរណ៍កម្មឆ្នាំណា ៩៦?

វ៉ុនៈ មិនដឹងជា៩០ប៉ុន្មានទេ ខ្ញុំមិនបានចាំផងខ្ញុំមិនបានគិតផង ។

ប៊ុនថនៈ ចឹងចង់សុំអ៊ីមួយដែល ដូចថាមុនសមាហរណ៍កម្មនិងក្រោយសមាហរណ៍កម្មហើយមានប្លែកអីយ៉ាងម៉េចដែរ ដូចជាជីវភាពរស់នៅអី?

វ៉ុនៈ ជីវភាពយ៉ាប់ដែលឥឡូវយើងធ្វើអីមិនកើតហ្នឹងគេហ្នឹង ។

ប៊ុនថនៈ បាទ ។

វ៉ុនៈ កាលមុនធូរកាលសំបក់បើកហូប យើងចាស់ចឹងទៅឯជនចឹងយើងខំទៅបើយើងមិនរកអត់អីហូប ដើរស៊ីឈ្នួលគេទៅ ។

ប៊ុនថនៈ បាទ! ចឹងអ៊ីរាល់ថ្ងៃក្រៅពីធ្វើចំការធ្វើអីវិញអ៊ី?

វ៉ុនៈ ថាអត់មានធ្វើអីទេឥឡូវខ្ញុំចាស់ហើយ នៅផ្ទះជួយមើលកូនចៅឲ្យគេទៅច្រូតស្រូវចេះតែទៅជួយគេតិចៗហ្នឹង ។

ប៊ុនថនៈ ចឹងចង់សួរអ៊ីមួយទៀតកាលជំនាន់បដិវត្តចឹងមានធ្លាប់ជួយអ្នកផ្សេងទេ?

វ៉ុនៈ ជួយ ។

ប៊ុនថនៈ បាទ!ដូចថាជួយឲ្យជាចំណីអាហារជួយជាម្ហូបអារជួយជាស្អីដែលអ៊ីអាចជួយបានណាស់អ៊ីមានធ្លាប់ជួយគេផ្សេងដែរ?

វ៉ុនៈ ជួយដូចជាទឹកដោះគោ ម៉ីស្ករស្អីទៅហូរហែរ ។

ប៊ុនថនៈ ចឹងអ៊ីធ្លាប់ជួយដែរ?

វ៉ុនៈ ជួយទៅវិញទៅមកគេជួយឯង ឯងជួយគេជួយគ្នាក្នុងគ្រាមានអាសន្នឧបមាថាគ្រួសារទ័ពទៅឯនោះចាស់ៗនេះឯងជួយមើលប្រពន្ធកូនសម្រាលកូនជួយមើលទៅដងទឹកអីឲ្យទៅជួយបបរបាយអីឲ្យហូបទៅ ជួយគ្នាទៅវិញទៅមកដឹងទុក្ខធុរៈគ្នា ។

ប៊ុនថនៈ តែចង់និយាយថា កាលមុនមកហ្នឹងអីអ៊ី ដូចថាមុនអ៊ីនៅកងអីចឹងនៅខាងកោះកុងអីចឹងណាស់មានធ្លាប់ជួយគេដែរ?

វ៉ុនៈ នៅហ្នឹងមានអីនៅកងទាំងអស់គ្នាហ្នឹង ។

ប៊ុនថនៈ បាទ ។

វ៉ុនៈ ចេះជួយគ្នាទៅ កាលពីដើមសាមគ្គីគ្នាច្រើនណាស់ មិនដូចឥឡូវទេ ឥឡូវរាងខ្ទីសចិត្តបន្តិចមិនដូចពូមុនទេបែកសាមគ្គីគ្នា ។

ប៊ុនថនៈ ខ្ទីសចិត្តយ៉ាងម៉េចទៅ?

វុនៈ ឧបមាគេមានរាងធូរធារគេ គេមិនសូវគិតយើងអត់ទេ គេមិនសូវមើលមុនយើងទេ គេមាន គេមានតែគេទៅ យើងអ្នកក្រគេមិនសូវរវីរវល់ ពីមុនសាមគ្គីគ្នាបានល្អណាស់ ។

ប៊ុនថនៈ បាទ ។

វុនៈ អ្នកដែលធ្លាប់ស្គាល់គ្នាពីមុនមកក៏មិនសូវដែរ គេមិនសូវរាក់ទាក់ជាមួយយើងព្រោះយើងក្រ ។

ប៊ុនថនៈ ចឹងកាលថ្ងៃមុនអឹមានបានចូលរួមប្រជុំគេនៅវត្តដែរ?

វុនៈ អត់បានទៅទេ អ្នកដើរមិញបានទៅ ។

ប៊ុនថនៈ បាទ ។

វុនៈ បើសៀវភៅបាន ម៉ាឡៃអីបាន អានី អឹឡាយ អឹជឿនអត់បានទៅទេ ។

ប៊ុនថនៈ បាទ ។

វុនៈ បានអឹឡាយ បានអានី កាលហ្នឹងរើសប៉ុន្មាននាក់ដូចជា១០នាក់ ឃើញតាមប្រវត្តិឃើញអឹ ឃើញអាណិតខ្លោចចិត្តអឹណាស់ គាត់ហ្នឹងត្រួសត្រាយផ្លូវឲ្យពួកខ្ញុំដើរកុំអីខ្ញុំអត់មានបានរស់រានមានជីវិត កុំអីពួកខ្ញុំស្លាប់៧៩អស់ ។

ប៊ុនថនៈ បាទ ។

វុនៈ កុំបានគាត់ជួយពួកខ្ញុំនេះឯង បានត្រួសត្រាយផ្លូវទប់ស្កាត់ដីយើងនេះ យើងមកធ្វើជារបងចឹងអត់មានពីណាមកលូកដៃទេ ។

ប៊ុនថនៈ បាទ ។

វុនៈ កុំតែបានប្រវត្តិអឹៗហ្នឹងមានអីតស៊ូបានមានដីមានចែកកូនចែកចៅទេ ។

ប៊ុនថនៈ បាទ ។

វុនៈ រិចតែកន្ទាលរត់ទៅលិចទៅកើតគ្រប់គ្នា ។

ប៊ុនថនៈ ចឹងខ្ញុំអត់មានអីសួរអឹហើយខ្ញុំអរគុណច្រើន ។

វុនៈ ចាស ។

**«ចប់»**